ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខៈ......០០៤/១១......គ.ម.ក ប្រ.ក.

# ប្រកាស

# ស្តីពី

# ការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

* * * * *

## ឧបនាយករដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុថ្ងៃះទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គមក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh

Downloaded from http://www.khmerlaws.com

- បានឃើញប្រកាសលេខ ០០៤ គមក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ
- បានឃើញសំណើសុំការពិនិត្យ និងអនុម័ត លើវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១០
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១

## ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១១

**គាត ឈន់**

**កន្លែងទទួល ÷**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



Downloaded from http://www.khmerlaws.com

ឧបសម្ព័ន្ធប្រកាសលេខ ..០០៨/១១ គ.ម.ក. ប្រ.ក.
ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១១

# វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

*****

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.- គោលបំណង**

គោលបំណងនៃវិធាននេះ គឺដើម្បីកំណត់អំពីគោលការណ៍នានាដែលចាំបាច់សម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា **ផ.ម.ក.**) អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

**ប្រការ ២.- និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងវិធាននេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន÷

**-បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដំបូង** សំដៅដល់បុគ្គលដែលមានបំណងធ្វើសំណើចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ដែលមិនធ្លាប់បានចុះបញ្ជីលក់នៅ **ផ.ម.ក.**។

**-បុគ្គលចុះបញ្ជីលក់មូលបត្រ** សំដៅដល់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយបានចុះបញ្ជីលក់មូលបត្រនោះនៅ **ផ.ម.ក.**។

**-ក្រុមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ** សំដៅដល់ភាគហ៊ុនិក និងបុគ្គលពាក់ព័ន្ធពិសេសនៃក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេរបស់ក្រុមហ៊ុន។ ក្នុងករណីនេះ ភាគហ៊ុនដែលកាន់កាប់ក្នុងគោលបំណងវិនិយោគជាកញ្ចប់ដោយវិនិយោគិនស្ថាប័ន ត្រូវបានដកចេញពីការគណនាចំនួនភាគហ៊ុនដែលកាន់កាប់ដោយក្រុមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ។



Downloaded from http://www.khmerlaws.com

## ជំពូកទី ២
## ការចុះបញ្ជីលក់មូលបត្រ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**ប្រការ ៣.- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ**

របាយការណ៍ហិរញ្ញវត្ថុដែលត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវរៀបចំឡើង និងធ្វើសវនកម្ម ដោយអនុលោមតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ ព្រមទាំងបទប្បញ្ញត្តិជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ព័ត៌មានហិរញ្ញវត្ថុលម្អិតដែលតម្រូវនៅក្នុងវិធាននេះ ត្រូវរៀបចំឡើងដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

**ប្រការ ៤.- ការមិនសងត្រលប់ទៅវិញនូវឯកសារពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជី និង ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ**

រាល់ឯកសារពាក់ព័ន្ធនឹងពាក្យស្នើសុំដើម្បីពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ ដែលតម្រូវដោយវិធាននេះ មិនត្រូវប្រគល់ជូនបុគ្គលស្នើសុំវិញនោះទេ ទោះបីពាក្យស្នើសុំនោះត្រូវបានបដិសេធ ឬត្រូវបានដកទៅវិញក៏ដោយ។

### ផ្នែកទី ២
### លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

**ប្រការ ៥.- ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ**

បុគ្គលដែលមានបំណងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ **គ.ម.ក.** ត្រូវឆ្លងកាត់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។

**ប្រការ ៦.- ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ**

បុគ្គលដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ត្រូវភ្ជាប់មកជាមួយនូវឯកសារមក **គ.ម.ក.** ដូចខាងក្រោម :

១- ព័ត៌មានទូទៅ :

ក- ឈ្មោះរបស់ក្រុមហ៊ុនជាភាសាខ្មែរ និងអក្សរឡាតាំង។



Downloaded from http://www.khmerlaws.com

ខ-អាសយដ្ឋានក្រុមហ៊ុន។

គ-កាលបរិច្ឆេទបង្កើតក្រុមហ៊ុន។

ឃ-កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន។

ង-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។

ច-លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ។

២-ព័ត៌មានអំពីបុគ្គលតំណាងក្រុមហ៊ុន : អត្តសញ្ញាណបុគ្គលតំណាងក្រុមហ៊ុន។

៣-ព័ត៌មានអំពីភាគហ៊ុនិក : អត្តសញ្ញាណភាគហ៊ុនិក។

៤-ព័ត៌មានអំពីលក្ខខណ្ឌបរិមាណ :

ក-មូលធនភាគហ៊ុនិកសរុបគិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ។

ខ-ប្រាក់ចំណេញសុទ្ធ ០៣ (បី)ឆ្នាំចុងក្រោយ។

គ-របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម ០៣ (បី) ឆ្នាំចុងក្រោយ។

ឃ-ប្រភេទមូលបត្រដែលត្រូវបោះផ្សាយ និងជួញដូរនៅ **ផ.ម.ក.**។

**ប្រការ ៧.- ការជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជី**

**ផ.ម.ក.** ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រទៅបុគ្គលដាក់ពាក្យស្នើសុំក្នុងរយៈពេល យ៉ាងយូរបំផុតត្រឹម ០១ (មួយ) ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំ។

ករណី **ផ.ម.ក.** បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្ររបស់បុគ្គលដាក់ពាក្យស្នើសុំ **ផ.ម.ក.** ត្រូវពន្យល់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ហើយបុគ្គលដាក់ពាក្យស្នើសុំអាចស្នើសុំការបំភ្លឺពី **ផ.ម.ក.**។ បុគ្គលដែលត្រូវបានបដិសេធ អាចធ្វើការតវ៉ាមក **គ.ម.ក.** ចំពោះការបដិសេធនោះ ដើម្បីពិនិត្យនិងសម្រេច។

## ផ្នែកទី ៣
## លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ

**ប្រការ ៨.- នីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ**

បុគ្គលដែលទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រនៅ **ផ.ម.ក.** ត្រូវបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ **ផ.ម.ក.** ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីមូលបត្រត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម។

**ប្រការ ៩.- ឯកសារដែលត្រូវផ្តល់ជូន ផ.ម.ក.**

ក្នុងការបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រផ្លូវការនៅ **ផ.ម.ក.** បុគ្គលដែលទទួលបានការបញ្ជាក់



Downloaded from http://www.khmerlaws.com

ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ត្រូវផ្ដល់ជូន **ផ.ម.ក.** នូវឯកសារដូចខាងក្រោម÷

១-ឯកសារផ្ដល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។

២-ឯកសារបញ្ជាក់អំពីការទូទាត់បរិវិសកម្មមូលបត្រ។

៣-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

៤-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយភ្នាក់ងារទូទាត់។

៥-របាយការណ៍បែងចែកមូលបត្រ។

៦-លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

**ប្រការ ១០.- ការចុះបញ្ជីលក់មូលបត្រជាផ្លូវការ**

បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវ និងពេញលេញដូចមានចែងក្នុងប្រការ ៩ នៃវិធាននេះ **ផ.ម.ក.** ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ **ផ.ម.ក.** ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

**ប្រការ ១១.- កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ**

មុននឹងត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ **ផ.ម.ក.** បុគ្គលទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រតាមគំរូដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី ១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

**ប្រការ ១២.- លក្ខខណ្ឌតម្រូវជាតួលេខ**

បុគ្គលដែលទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ **ផ.ម.ក.** ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម លើកលែងតែមានការកំណត់លក្ខ-ខណ្ឌផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.** :

១-ចំនួនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% (មួយភាគរយ) : ចំនួនភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១% (មួយភាគរយ) ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

២-ចំនួនភាគហ៊ុនរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង១% (មួយភាគរយ) : ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតតិចជាង ១% (មួយភាគរយ) ត្រូវមានចំនួនសរុបចាប់ពី ២០០.០០០ (ពីរសែន) ភាគហ៊ុនឡើងទៅ ឬ



Downloaded from http://www.khmerlaws.com

១៥% (ដប់ប្រាំភាគរយ) នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប ដោយយកចំនួនណាមួយដែលធំជាងគេ។

**ប្រការ ១៣.- លក្ខខណ្ឌតម្រូវមិនមែនជាតួលេខ**

បុគ្គលដែលទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ **ផ.ម.ក.** ដោយត្រូវបំពេញលក្ខខណ្ឌតម្រូវមិនមែនជាតួលេខដូចខាងក្រោម :

១-មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេក្នុងរយៈពេល ០១ (មួយ) ឆ្នាំចុងក្រោយរហូតដល់កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

២-មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

## **ជំពូកទី ៣**

## **លក្ខខណ្ឌ និងនីតិវិធីនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ**

**ប្រការ ១៤.- លក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ**

**ផ.ម.ក** ត្រូវដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការនូវមូលបត្ររបស់ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រក្នុងករណីណាមួយដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.** :

១-ករណីដែលក្រុមហ៊ុនមិនបានដាក់របាយការណ៍ប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធចុងក្រោយក្នុងអំឡុងពេល ០៣ (បី) ខែ បន្ទាប់ពីកាលវសានដែលកំណត់ដោយ **គ.ម.ក.**។

២-ករណីដែលយោបល់របស់សវនករនៅក្នុងរបាយការណ៍សវនកម្មរបស់ក្រុមហ៊ុន មានយោបល់ជំទាស់ ឬបដិសេធ សម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំ។

៣-ករណីដែលរបាយការណ៍ប្រចាំឆ្នាំបានបង្ហាញថា មូលធនភាគហ៊ុនិករបស់ក្រុមហ៊ុនបានថយចុះក្នុងរយៈពេល ០២ (ពីរ) ឆ្នាំជាប់គ្នា ច្រើនជាង ៥០% (ហាសិបភាគរយ)។

៤-ករណីដែលមានការបំពានលើកាតព្វកិច្ចផ្តល់ព័ត៌មានជាញឹកញាប់។

៥-ករណីដែលក្រុមហ៊ុនមិនអាចទូទាត់ជាស្ថាពរលើផលបត្រពាណិជ្ជកម្ម ឬមូលប្បទានបត្រដែលខ្លួនបានចេញ ឬប្រតិបត្តិការរបស់ខ្លួនជាមួយធនាគារពាណិជ្ជត្រូវបានព្យួរ។

៦-ករណីដែលក្រុមហ៊ុនស្ថិតក្រោមករណីណាមួយ នៃមូលហេតុរំលាយក្រុមហ៊ុនយោងតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧-ករណីដែលក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ ត្រូវបានដាក់កំហិតក្នុងការផ្ទេរកម្មសិទ្ធិភាគហ៊ុន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានអនុវត្តនោះទេ ចំពោះករណីដែលការដាក់កំហិតត្រូវបានចាត់ទុកថាមិន



Downloaded from http://www.khmerlaws.com

ប៉ះពាល់ដល់ការជួញដូរនៅលើទីផ្សារ ពីព្រោះការដាក់កំហិតនេះត្រូវធ្វើឡើងដោយច្បាប់ផ្សេងទៀតដែលមិនពាក់ព័ន្ធដល់វិស័យមូលបត្រ។

**ប្រការ ១៥.- ការជូនដំណឹងជាសាធារណៈ និងការអនុញ្ញាតលើការជួញដូរលើមូលបត្រដែលដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ**

នៅពេលដកចេញពីបញ្ជីនូវមូលបត្រចុះបញ្ជីលក់មូលបត្រជាផ្លូវការណាមួយ **ផ.ម.ក.** ត្រូវផ្សព្វផ្សាយជាសាធារណៈអំពីការដកពីបញ្ជីនូវមូលបត្រដែលពាក់ព័ន្ធ។

ករណីដកចេញពីបញ្ជីនូវមូលបត្រណាមួយ **ផ.ម.ក.** អាចអនុញ្ញាតឱ្យមានការជួញដូរបន្តលើមូលបត្រនោះ សម្រាប់រយៈពេល ១០ (ដប់) ថ្ងៃ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

## ជំពូកទី ៤

## ការគ្រប់គ្រងលើមូលបត្រដែលបានចុះបញ្ជីលក់

**ប្រការ ១៦.- កាតព្វកិច្ច និងនីតិវិធីផ្តល់ព័ត៌មាន**

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិត្រូវដាក់ជូន **ផ.ម.ក.** ឱ្យទាន់ពេលវេលានូវឯកសារផ្តល់ព័ត៌មាន និងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចផ្តល់ព័ត៌មានរបស់ខ្លួន ស្របតាមការកំណត់របស់**គ.ម.ក.**។

**ប្រការ ១៧.- កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុន**

បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រដំបូង ត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យា ដែលក្នុងនោះក្រុមភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនភាគច្រើនលើសលប់ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុនដែលខ្លួនកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ០១ (មួយ) ឆ្នាំ និងភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥% (ដប់ប្រាំភាគរយ) ឡើងទៅ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុនដែលខ្លួនកាន់កាប់យ៉ាងហោចណាស់ សម្រាប់រយៈពេល ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីចុះបញ្ជីលក់មូលបត្រដំបូង។

**ប្រការ ១៨.- ការព្យួរការជួញដូរ និងការចាប់ផ្តើមជួញដូរជាថ្មី**

**ផ.ម.ក** អាចព្យួរការជួញដូរមូលបត្រក្នុងករណីណាមួយដូចខាងក្រោម :

១-ករណីភាគហ៊ុនចុះបញ្ជីលក់មួយផ្នែក ឬទាំងស្រុង មានការក្លែងបន្លំ។

២-ករណីដែលស្ថិតក្រោមលក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការណាមួយនៃប្រការ ១៤ ដែលវិធានការនៃការដកចេញពីបញ្ជីលក់មូលបត្រមិនទាន់បានអនុវត្ត។



Downloaded from http://www.khmerlaws.com

៣-ករណីមានការបំបែក ឬការបង្រួមមូលបត្រកម្មសិទ្ធិ ឬតាមសំណើរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៤-ករណីមានការសម្រេចពីអគ្គនាយកនៃ គ.ម.ក.។

ការព្យួរការជួញដូរមូលបត្រ ស្របតាមកថាខណ្ឌទី ១ ត្រូវបានអនុវត្តរហូតដល់មូលហេតុនៃការព្យួរការជួញដូរត្រូវបានដោះស្រាយរួច លើកលែងតែមានការសម្រេចបន្ថែមពីអគ្គនាយកនៃ គ.ម.ក.។

**ប្រការ ១៩.- ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែម**

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ដែលមានបំណងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែមត្រូវអនុវត្តនីតិវិធីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិដូចមានចែងក្នុងវិធាននេះ។

**ប្រការ ២០.- ពាក្យស្នើសុំកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ**

ករណីមានការកែប្រែឈ្មោះក្រុមហ៊ុន តម្លៃចារឹករបស់មូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ ឬចំនួនមូលបត្រកម្មសិទ្ធិបោះផ្សាយ បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិត្រូវបំពេញនីតិវិធីកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.។

**ប្រការ ២១.- ការជូនដំណឹងអំពីការក្លែងបន្លំផ្ទេរមូលបត្រ**

ករណីមានការជូនដំណឹងជាលាយលក្ខណ៍អក្សរមក គ.ម.ក. អំពីករណីមានការក្លែងបន្លំក្នុងការផ្ទេរមូលបត្រកម្មសិទ្ធិ បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិត្រូវជូនដំណឹងភ្លាមមក ផ.ម.ក.។ ការជូនដំណឹងមក ផ.ម.ក. នេះ អាចធ្វើឡើងតាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

## ជំពូកទី ៥
## ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ

**ប្រការ ២២.- ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ និងការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ**

បុគ្គលស្នើសុំការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ត្រូវបង់ថ្លៃសេវាចំនួន ៤.០០០.០០០(បួនលាន) រៀលជូន ផ.ម.ក.។

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ត្រូវបង់ថ្លៃសេវាសម្រាប់ការចុះបញ្ជីមូលបត្រជូន ផ.ម.ក. ស្មើនឹង 0,១0% (សូន្យក្បៀសដប់ភាគរយ) នៃចំនួនទឹកប្រាក់មូលធនូបនីយកម្មទីផ្សារសរុប (Market Capitalization) ដោយគិតតាមថ្លៃបោះផ្សាយលក់លើកដំបូង។



Downloaded from http://www.khmerlaws.com

**ប្រការ ២៣.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ**

បុគ្គលចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំទៅតាមមូលធនទូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយដូចខាងក្រោម :

១-ប្រសិនបើមូលធនទូបនីយកម្មទីផ្សារ តិចជាងឬស្មើនឹង ១២.០០០.០០០.០០០ (ដប់ពីរពាន់-លាន) រៀល ត្រូវបង់សេវា ៣.០០០.០០០(បីលាន) រៀល។

២-ប្រសិនបើមូលធនទូបនីយកម្មទីផ្សារច្រើនជាង ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល និងតិចជាងឬស្មើនឹង ៤០.០០០.០០០.០០០(សែសិបពាន់លាន) រៀល ត្រូវបង់ដូចខាងក្រោម :

ក-មូលធនទូបនីយកម្មទីផ្សារស្មើនឹង ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល ត្រូវបង់សេវា ៣.០០០.០០០(បីលាន) រៀល។

ខ-មូលធនទូបនីយកម្មទីផ្សារនៅសល់ត្រូវបង់ ០,០២%(សូន្យក្បៀសពីរភាគរយ)។

៣- មូលធនទូបនីយកម្មទីផ្សារច្រើនជាង ៤០.០០០.០០០.០០០ (សែសិបពាន់លាន)រៀល និងតិចជាងឬស្មើនឹង ២០០.០០០.០០០.០០០(ពីររយពាន់លាន) រៀល ត្រូវបង់ដូចខាងក្រោម :

ក-មូលធនទូបនីយកម្មទីផ្សារស្មើនឹង ១២.០០០.០០០.០០០ (ដប់ពីរពាន់លាន) រៀល ត្រូវបង់សេវា ៣.០០០.០០០(បីលាន) រៀល។

ខ-មូលធនទូបនីយកម្មទីផ្សារស្មើនឹង ២៨.០០០.០០០.០០០ (ម្ភៃប្រាំបីពាន់លាន)រៀល ត្រូវបង់សេវា ៥.៦០០.០០០(ប្រាំលាន និងប្រាំមួយសែន) រៀល។

គ-មូលធនទូបនីយកម្មទីផ្សារ នៅសល់ត្រូវបង់សេវា ០,០១៥%(សូន្យក្បៀសមួយភាគរយកន្លះ)។

៤-មូលធនទូបនីយកម្មទីផ្សារច្រើនជាង ២០០.០០០.០០០.០០០(ពីររយពាន់លាន) រៀល ត្រូវបង់ដូចខាងក្រោម ÷

ក- មូលធនទូបនីយកម្មទីផ្សារ ស្មើនឹង១២.០០០.០០០.០០០(ដប់ពីរពាន់លាន) រៀល ត្រូវបង់សេវា ៣.០០០.០០០(បីលាន) រៀល។

ខ- មូលធនទូបនីយកម្មទីផ្សារ ស្មើនឹង ២៨.០០០.០០០.០០០ (ម្ភៃប្រាំបីពាន់លាន) រៀល ត្រូវបង់សេវា ៥.៦០០.០០០(ប្រាំលាន និងប្រាំមួយសែន) រៀល។

គ- មូលធនទូបនីយកម្មទីផ្សារស្មើនឹង ១៦០.០០០.០០០.០០០ (មួយរយហុកសិបពាន់លាន) រៀល ត្រូវបង់សេវា ០,០១៥ % (សូន្យក្បៀសមួយភាគរយកន្លះ)ឬស្មើនឹង ២៤.០០០.០០០ (ម្ភៃបួនពាន់លាន) រៀល។

ឃ-មូលធនទូបនីយកម្មទីផ្សារ នៅសល់ត្រូវបង់សេវា ០,០០៥%។



Downloaded from http://www.khmerlaws.com

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

**ប្រការ ២៤.- អញ្ញត្រកម្ម**

ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំដំបូងនៃការអនុវត្តវិធាននេះ តាមការជាក់ស្តែង **ផ.ម.ក.** អាចស្នើសុំមកអគ្គនាយកនៃ **គ.ម.ក.** ក្នុងការបន្ធូរបន្ថយលើលក្ខខណ្ឌតម្រូវពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការចុះបញ្ជីលក់មូលបត្រជាផ្លូវការដល់បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ។

*****



Downloaded from http://www.khmerlaws.com